ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមគោរពជូន
សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា
នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៦

សម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហាន និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមជូននូវសេចក្តីសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្តេចមហារដ្ឋសភាធិការធិបតី** ក្នុងឱកាសដ៏មហាប្រសើរ ពោរពេញដោយក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មី **ឆ្នាំសកល២០២៦** ខាងមុខនេះ: សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងខ្លាំងក្លា បញ្ញាញាណវាងវៃ ជំនាញយុទ្ធវិធីឈរ ដើម្បីបន្តដឹកនាំស្ថាប័នរដ្ឋសភាឱ្យមានការរីកចម្រើនថ្មីៗបន្តទៀត។

នាឱកាសដ៏សោមនស្សរីករាយនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រចំពោះកិច្ចខិតខំប្រឹងប្រែងព្យាយាមរឿយហាត់របស់ **សម្តេច** ប្រធានរដ្ឋសភា ដែលបានយកអស់កម្លាំងកាយចិត្ត ព្រមទាំងប្រាជ្ញាស្មារតីដ៏ឈ្លាសវៃ និងប៉ិនប្រសប់ ប្រកបដោយគតិបណ្ឌិត សក្តានុពល ឧត្តមភាព ភក្តីភាពក្នុងការបម្រើជាតិ សាសនា ព្រះមហាក្សត្រ ព្រមជាមួយគ្នានេះ: **សម្តេច** គឺជាមគ្គុទ្ទេសក៍ដ៏ឆ្នើមក្នុងការដើរតួនាទីស្ថាប័នរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវសមិទ្ធផលជាបន្តបន្ទាប់គួរឱ្យស្ងប់ស្ងែង និងបានជំរុញឱ្យស្ថាប័នរដ្ឋសភាដែលជាស្ថាប័ននីតិបញ្ញត្តិរបស់ជាតិមានការរីកចម្រើនឥតឈប់ឈរ រួមចំណែកដល់ការលើកកម្ពស់នីតិរដ្ឋស្របតាមបំណងប្រាថ្នាដែលប្រជាជនចង់បាន។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរជ័យ សិរីមង្គល វិបុលសុខ ជូនចំពោះ: **សម្តេចមហារដ្ឋសភាធិការធិបតី** និងក្រុមគ្រួសារ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញថ្ងៃទី ១៥ ខែ ភ្នំ ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

ទីស្នាក់ការដឹកនាំក្រសួង សង្កាត់មិត្តភាព ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៩ email: generalsec@mod.gov.kh

សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

អរគុណសន្តិភាព! អរគុណនយោបាយឈ្នះឈ្នះ!